ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

សំណុំរឿងរដ្ឋប្បវេណី
លេខ: ៣៥៥
ចុះថ្ងៃទី: ០៧-០៣-២០១១
សាលក្រមរដ្ឋប្បវេណី
លេខ: ៥៧ "ណ"
ចុះថ្ងៃទី: ២១-០៩-២០១១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់លើកទីមួយនៅថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ ២០១១ លើសំណុំរឿងរដ្ឋប្បវេណីលេខ ៣៥៥ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១ ដែលមានសមាសភាពជំនុំជម្រះដូចតទៅ:

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-រវាងដើមចោទឈ្មោះ [redacted] លឹមប៉ូល ភេទប្រុស មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ១០៥ ផ្លូវជាតិលេខ១ ភូមិតាងៅ សង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ

-ចុងចម្លើយឈ្មោះ [redacted] កុកង៉ាន់ ភេទប្រុស អាយុ ៤៤ឆ្នាំ មុខរបរនាយកក្រុមហ៊ុន បេសតានហ្គារមេនLTD មានទីលំនៅផ្ទះលេខ២៣៣ ផ្លូវមហាវិថីនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ

**ដែលមានកម្មវត្ថុបណ្តឹង:**

-ប្តឹងទាមទារប្រាក់

## អង្គហេតុ និងចំណុចវិវាទ

<u>១-សាលក្រមទាមទារដោយដើមចោទ</u>

-ទាមទារប្រាក់ឈ្នួលពីចុងចម្លើយចំនួន៤៧០៥០$ (បួនម៉ឺនប្រាំពីរពាន់សុន្យរយហាសិបដុល្លារអាមេរិក)

-ទាមទារការប្រាក់តាមច្បាប់ចំនួន ៥% ក្នុងមួយឆ្នាំ គិតចាប់ពី ខែតុលា ឆ្នាំ២០០៨ រហូតដល់ចុងចម្លើយសងប្រាក់រួច ។

-ទាមទារជម្ងឺចិត្ត. ថ្លៃខូចខាតផលប្រយោជន៍. ថ្លៃសេវាកម្មច្បាប់ និងការចំណាយ សំរាប់រឿងក្តីសរុបចំនួន ៤០.០០០.០០០(សែសិបលានរៀល) ។

-ការចំណាយលើប្រាក់ប្រដាប់ក្តី និងប្រាក់ពន្ធផ្សេងៗ ជាបន្ទុកភាគីចុងចម្លើយ ។

-ស្នើសុំអោយមានការអនុវត្តជាបណ្តោះអាសន្នលើសាលក្រមនេះ ។

២-ការអះអាងរបស់គូភាគី:

ក/-ការអះអាងរបស់លោក [redacted] ជាមេធាវីតំណាងដោយអណត្តិរបស់ដើមចោទថា: ខ្លួនសុំរក្សាការប្តឹងទាមទារដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១ និងរក្សាដូចក្នុងកំណត់ហេតុត្រៀមទាញហេតុផលទាំងពីរលើកគឺ

-ចំណុចទី១ សុំឲ្យចុងចម្លើយសងប្រាក់ឈ្នួលទីតាំងចំនួន ៤៧០៥០$ (បួនម៉ឺនប្រាំពីរពាន់សូន្យរយហាសិបដុល្លារអាមេរិក) ។

-ចំណុចទី២ សុំទាមទារការប្រាក់ចំនួន ៥% ក្នុង១ឆ្នាំ គិតចាប់ពីខែតុលា ឆ្នាំ ២០០៨ រហូតដល់ចុងចម្លើយសងប្រាក់គ្រប់ចំនួន ។

-ចំណុច៣ សុំទាមទារជម្ងឺចិត្ត , ថ្លៃខូចខាតផលប្រយោជន៍ , ថ្លៃសេវាកម្មច្បាប់ និងការចំនាយសម្រាប់រឿងក្តី សរុបជាប្រាក់ចំនួន ៤០,០០០,០០០៛ (សែសិបលានរៀល) ។

-ចំណុច៤ សុំឲ្យចុងចម្លើយទទួលបន្ទុកលើកការចំណាយបង់ប្រាក់ប្រដាប់ក្តី និងប្រាក់ពន្ធផ្សេងៗ ។

-ចំណុច៥ សុំឲ្យតុលាការប្រកាសថា សាលក្រមនេះមានអានុភាពអនុវត្តជាបណ្តោះអាសន្ន។

យោងកិច្ចសន្យាជួលដី និងអាគារចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ ភាគីចុងចម្លើយបានជួលដី និងអាគារលេខ ២៣៣ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ហៅ ឃ្លាំងបេ ពីកូនក្តីខ្លួនឈ្មោះ [redacted] លឹមប៉ុល ក្នុងតម្លៃ ៦៥០០$ (ប្រាំមួយពាន់ប្រាំរយដុល្លាអាមេរិក) ក្នុងមួយខែ ការបង់ប្រាក់ឈ្នួលរបស់ចុងចម្លើយប្រព្រឹត្តទៅជាធម្មតា ប៉ុន្តែចាប់ពីខែតុលា ឆ្នាំ ២០០៨ រហូតមកដល់ខែ មិថុនា ឆ្នាំ ២០០៩ ភាគីចុងចម្លើយមិនបានបង់ប្រាក់ឈ្នួលជាកាតព្វកិច្ចមកឲ្យកូនក្តីខ្លួនទេ ។ ក្រោយមកនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ភាគីចុងចម្លើយបានធ្វើលិខិតទទួលស្គាល់ថា ពិតជានៅជំពាក់ប្រាក់កូនក្តីខ្លួនចំនួន ៥១០៥០$ (ប្រាំម៉ឺនមួយពាន់សូន្យរយហាសិបដុល្លារអាមេរិក) ។ ក្រោយពីបានធ្វើលិខិតទទួលស្គាល់បំណុលរួចហើយ ភាគីចុងចម្លើយនៅមិនទាន់ បានធ្វើការទូរទាត់ប្រាក់ជំពាក់ការជួលទីតាំងមកឲ្យកូនក្តីខ្លួនទេ ទោះបីជាមានការទាមទារពីកូនក្តី ខ្លួនយ៉ាងណាក៏ដោយ ទើបកូនក្តីខ្លួនបានសម្រេចដាក់ពាក្យប្តឹងមកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីឲ្យជួយចេញសាលក្រមឲ្យចុងចម្លើយសងប្រាក់ឈ្នួលនេះមកកូនក្តីខ្លួនវិញ ។

-លោក [redacted] បានធ្វើការអះអាងថា: នៅតំណាក់កាលត្រៀមទាញហេតុផលលើកទី២ មានចំណុចចំនួនពីរដែលលោកមេធាវីតំណាងដោយអណត្តិរបស់ចុងចម្លើយបានទទួលស្គាល់ គឺចំណុចទី១ មេធាវីរបស់ចុងចម្លើយទទួលស្គាល់ថា ចុងចម្លើយពិតជាជំពាក់ប្រាក់ដើមចោទចំនួន ៥១០៥០$ (ប្រាំម៉ឺនមួយពាន់សូន្យរយហាសិបដុល្លារអាមេរិក) ចំណុចទី២ គឺវិក័យប័ត្របង់ប្រាក់ចំនួន ២០០០$ (ពីរពាន់ដុល្លារអាមេរិក) ចំនួនពីរសន្លឹករបស់ចុងចម្លើយ ខ្លួនបានសួរកូន





Scanned with CamScanner

ក្តីខ្លួន រួចហើយ គាត់ថាចុងចម្លើយបានសងប្រាក់ចំនួន ៤០០០$ (បួនពាន់ដុល្លារអាមេរិក) តាមវិក័យប័ត្រ ទាំងពីរសន្លឹកនៅក្រោយពេលធ្វើកិច្ចសន្យាជំពាក់ប្រាក់ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ប្រាកដ មែន ហេតុនេះកូនក្តីខ្លួនឯកភាពកាត់ចេញចំនួនទឹកប្រាក់ ៤០០០$ (បួនពាន់ដុល្លារអាមេរិក) គឺ ចុងចម្លើយនៅជំពាក់កូនក្តីខ្លួនតែ ៤៧០៥០$ (បួនម៉ឺនប្រាំពីរពាន់សូន្យរយហាសិបដុល្លារអាមេរិក) ប៉ុណ្ណោះ ។

ខ/-ការអះអាងរបស់លោក [redacted] ជាមេធាវីតំណាងដោយអណត្តិរបស់ចុងចម្លើយថា: សុំបដិសេធការប្តឹងទាមទាររបស់គូភាគីដើមចោទ ដោយមូលហេតុដូចតទៅ: កូនក្តីខ្លួនមិនបានបង់ប្រាក់ឈ្នួលទីតាំងនេះដោយសារលោក ឡូ លឹមប៉ូល មិនគោរពតាមកិច្ចសន្យាជួលទីតាំង ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ ដែលកិច្ចសន្យាជួលនោះមានថេរវេលា ១០ឆ្នាំ ដែលត្រូវធ្វើកិច្ច សន្យាជួល០៥ឆ្នាំម្តង ។ នៅពេលមុនចប់កិច្ចសន្យាជួល ភាគីអ្នកជួលត្រូវជូនដំណឹងមកឲ្យម្ចាស់ ទីតាំងយ៉ាងតិច៣ខែមុន ដើម្បីឲ្យភាគីទាំងពីរធ្វើកិច្ចសន្យាឡើងវិញ ។ ក្នុងរយៈពេលនោះកូនក្តីខ្លួន បានបំពេញកាតព្វកិច្ច ដោយទំនាក់ទំនងជាមួយលោក [redacted] លឹមប៉ូល ប៉ុន្តែទំនាក់ទំនងគ្នាមិនបាន ដោយគាត់រស់នៅឯក្រៅប្រទេស ។ នៅក្នុងឆ្នាំ ២០០៩ តំណាងរបស់លោក ឡូ លឹមប៉ូល បានមក ទារប្រាក់ថ្លៃឈ្នួលទីតាំងពីកូនក្តីខ្លួន នៅពេលនោះកូនក្តីខ្លួនមិនបានបង់ប្រាក់ឲ្យទេ ដោយស្នើសុំឲ្យ លោក [redacted] លឹមប៉ូល មកជួបដើម្បីធ្វើកិច្ចសន្យាថ្មីបន្តទៀត ។ ក្រោយមកលោក ឡូ លឹមប៉ូល ក៏បាន មកជួបកូនក្តីខ្លួន ហើយកូនក្តីខ្លួនបានស្នើសុំឲ្យលោក [redacted] លឹមប៉ូល ប្រាប់ថា គាត់អស់សិទ្ធិលើទីតាំង នោះហើយ ពេលលឺដូច្នេះ កូនក្តីខ្លួនបានស្នើសុំឲ្យលោក [redacted] លឹមប៉ូល ធ្វើការទូទាត់ប្រាក់គ្នាទៅវិញ ទៅមក គឺប្រាក់ដែលកូនក្តីខ្លួនបានជំពាក់ថ្លៃជួលទីតាំងជាមួយប្រាក់ដែលកូនក្តីខ្លួនកក់ ៤ខែ ស្មើ ២៦០០០$ (ពីរម៉ឺនប្រាំមួយពាន់ដុល្លារអាមេរិក) និងប្រាក់ថ្លៃតចរន្តអគ្គិសនីចំនួន ៣៧០០០$ (បីម៉ឺនប្រាំពីរពាន់ដុល្លារអាមេរិក) ដែលកូនក្តីខ្លួនបានចំណាយជំនួសដើមចោទ គឺដើមចោទត្រូវផ្ទេរមកឲ្យ កូនក្តីខ្លួនវិញ តាមកិច្ចសន្យាផ្ទេរអគ្គិសនី ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៤ ពេលនោះលោក [redacted] លឹមប៉ូល បានព្រមព្រៀងគ្នាថានឹងធ្វើការទូទាត់គ្នា ប៉ុន្តែនៅពេលដែលគាត់ធ្វើការសរុបទូទាត់ ទៅឃើញថា គាត់ត្រូវជំពាក់កូនក្តីខ្លួនវិញចំនួន ១៥៩៥០$ (មួយម៉ឺនប្រាំពាន់ប្រាំបួនរយហាសិប ដុល្លារអាមេរិក) ឃើញដូច្នេះលោក ឡូ លឹមប៉ូល ក៏បានគេចមិនចូលដោះស្រាយ និងមិនព្រមចុះកិច្ច សន្យាថ្មីបន្តទៀតឡើយ ។ ដោយសារការគេចវេសមិនព្រមធ្វើការដោះស្រាយនេះធ្វើឲ្យកូនក្តីខ្លួន ទទួលរងនូវការខាតបង់យ៉ាងធ្ងន់ធ្ងរ ដោយហេតុថាទីតាំងដែលកូនក្តីខ្លួនជួលពីលោក ឡូ លឹមប៉ូល ត្រូវបានរដ្ឋដកសិទ្ធិពីលោក ឡូ លឹមប៉ូល តាំងពីឆ្នាំ ២០០៩ កូនក្តីខ្លួនត្រូវជួលទីតាំងនេះបន្តពីអ្នក ផ្សេងទៀត ហេតុដូច្នេះទើបកូនក្តីខ្លួនបានដាក់ពាក្យបណ្តឹងតបប្តឹងទាមទារប្រាក់ពីដើមចោទវិញ ចំនួន ៦៣០០០$ (ប្រាំមួយម៉ឺនបីពាន់ដុល្លារអាមេរិក) គឺប្រាក់កក់ជួលទីតាំង ៤ខែ ស្មើ ២៦០០០$ (ពីរម៉ឺនប្រាំមួយពាន់ដុល្លារអាមេរិក) និងប្រាក់តបណ្តាញអគ្គិសនីចំនួន



Scanned with CamScanner

៣៧០០០$ (បីម៉ឺនប្រាំពីរពាន់ដុល្លាអាមេរិក) និងប្តឹងសុំទាមទារការខាតបង់ផ្សេងៗចំនួន ៥០,០០០,០០០៛ (ហាសិបលានរៀល) ហើយនិងសុំឲ្យតុលាការអនុវត្តលើសាលក្រមនេះ ។

-ចំពោះការលើកឡើងរបស់មេធាវីតំណាងដោយអណត្តិរបស់ដើមចោទដែលថា: សុំឲ្យកូនក្តីខ្លួនសងលុយកូនក្តីគាត់ចំនួន ៤៧០៥០$ (បួនម៉ឺនប្រាំពីរពាន់សូន្យរយហាសិបដុល្លាអាមេរិក) ដោយដើមចោទបានទទួលស្គាល់ថាកូនក្តីខ្លួនបានសងប្រាក់ចំនួន ៤០០០$ (បួនពាន់ដុល្លាអាមេរិក) ក្រោយធ្វើកិច្ចសន្យាជំពាក់ប្រាក់ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ។ អ្វីដែលពាក់ព័ន្ធនឹងការទាមទាររបស់ដើមចោទ កូនក្តីខ្លួនមិនជំទាស់ទេ តែគាត់លើកឡើងថា: ដើមចោទមិនទាន់បានធ្វើការទូទាត់ប្រាក់កក់ឈ្នួលឃ្លាំង ៤ខែ ស្មើ ២៦០០០$ (ពីរម៉ឺនប្រាំមួយពាន់ដុល្លាអាមេរិក) និងប្រាក់តចរន្តអគ្គិសនីដែលក្នុងប្រការបួននៃកិច្ចសន្យាបានចែងថា: ទុកទូទាត់ឈ្នួល៤ខែចុងក្រោយហើយ ដើមចោទមិនទាន់បានធ្វើការទូទាត់៤ខែចុងក្រោយឲ្យកូនក្តីខ្លួនទេ និងប្រាក់តចរន្តអគ្គិសនីដែលក្នុងកិច្ចសន្យាចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ បានចែងថា: ភាគីម្ចាស់ទីតាំងត្រូវទូទាត់ប្រាក់នោះ ឲ្យកូនក្តីខ្លួនវិញដែលសរុបទៅឃើញថា ដើមចោទមិនទាន់បានទូទាត់ប្រាក់កក់៤ខែ និងប្រាក់ត ចរន្តអគ្គិសនីសរុបស្មើ ៦៣០០០$ (ប្រាំមួយម៉ឺនបីពាន់ដុល្លាអាមេរិក) ទើបក្នុងពាក្យបណ្តឹងតបកូនក្តីខ្លួនប្តឹងសុំទាមទារឲ្យដើមចោទសងប្រាក់នោះមកកូនក្តីខ្លួនវិញ ។

-បើដើមចោទអះអាងថាមានការទូទាត់កាត់កងប្រាក់កក់ និងប្រាក់តចរន្តអគ្គិសនីមែន ប្រាកដជាមានឯកសារបញ្ជាក់ហើយដោយទឹកប្រាក់ច្រើន ប៉ុន្តែដើមចោទគ្មានឯកសារណាបញ្ជាក់ពីការទូទាត់ទេ សរុបទៅឃើញថា ដើមចោទនៅជំពាក់កូនក្តីខ្លួនវិញចំនួន ១៥៩៥០$ (មួយម៉ឺនប្រាំពាន់ប្រាំបួនរយហាសិបដុល្លាអាមេរិក) សុំឲ្យតុលាការសម្រេចឲ្យដើមចោទសងប្រាក់មកកូនក្តីខ្លួនចំនួន ១៥៩៥០$ (មួយ ម៉ឺនប្រាំពាន់ប្រាំបួនរយហាសិបដុល្លាអាមេរិក) ករណីកាត់កងគ្នារួច និងសុំឲ្យតុលាការសម្រេចបដិសេធការប្តឹងទាមទារសំណងជម្ងឺចិត្ត, ការប្រាក់, សេវាកម្មច្បាប់, សេវាកម្មសាធារណៈ និងប្រាក់ពន្ធរបស់ដើមចោទចោល ។

-សុំឲ្យដើមចោទសងការខូចខាតមកកូនក្តីខ្លួនចំនួន ៥០,០០០,០០០៛ (ហាសិបលានរៀល) ឬមួយតុលាការអាចសម្រេចឲ្យគូភាគីទូទាត់គ្នាទៅវិញទៅមកក៏បាន ក្នុងករណីបើដើមចោទនៅតែអះអាងថា បានទូទាត់កាត់កងគ្នាប្រាក់កក់ និងប្រាក់តចរន្តអគ្គិសនីឲ្យកូនក្តីខ្លួនរួច តុលាការអាចហៅគូភាគីមកស្បថចំពោះមុខតុលាការ ឬមួយតុលាការធ្វើលិខិតសួរទៅ EDC ថាតើម្ចាស់ប្រើចរន្តអគ្គិសនីនៅឃ្លាំងបេសព្វថ្ងៃជាឈ្មោះរបស់អ្នកណា ?

-លោក [redacted] ជាមេធាវីតំណាងដោយអណត្តិរបស់ដើមចោទបានធ្វើសេចក្តីសន្និដ្ឋានថា មេធាវីរបស់ចុងចម្លើយថាសុំច្រានចោលការទាមទាររបស់កូនក្តីខ្លួន ប៉ុន្តែគាត់បានទទួលស្គាល់ថាកូនក្តីគាត់ពិតជាមានជំពាក់ប្រាក់កូនក្តីខ្លួន ។ ចំពោះការលើកឡើងរបស់មេធាវីចុងចម្លើយដែលថាមិនទាន់មានការទូទាត់ប្រាក់តចរន្តអគ្គិសនី និងប្រាក់កក់ ហេតុអ្វីបានជា

ចុងចម្លើយធ្វើកិច្ចសន្យាទទួលស្គាល់ប្រាក់ជំពាក់ចុងក្រោយចំនួន ៥១០៥០$ (ប្រាំម៉ឺនមួយពាន់សូន្យរយហាសិបដុល្លារអាមេរិក) ពាក់ពន្ធ័អង្គហេតុឃើញថា ភាគីចុងចម្លើយបានទទួលស្គាល់ថាពិតជាជំពាក់ប្រាក់ឈ្នួលទីតាំងមែន ក្រៅពីប្រាក់ឈ្នួលទីតាំងឃើញថា ចុងចម្លើយនៅមិនទាន់បានទូទាត់ ប្រាក់ផ្សេងៗទៀត ទើបកូនក្តីខ្លួនបានហៅភាគីចុងចម្លើយមកធ្វើកិច្ចសន្យាទទួលស្គាល់បំណុល ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ប្រសិនបើមិនទាន់មានការទូទាត់ប្រាក់កក់៤ខែ ប្រាក់តចរន្ត អគ្គិសនីមែន ម្ល៉េះសមចុងចម្លើយមិនធ្វើកិច្ចសន្យាទទួលស្គាល់ប្រាក់ជំពាក់នោះទេ ។

-ចំពោះការលើកឡើងរបស់មេធាវីការពារចុងចម្លើយដែលសុំឲ្យតុលាការសួរ EDC ថាមានការផ្ទេរ ឬមិនមានការផ្ទេរឈ្មោះនោះ វាមិនចាំបាច់ទេ សុំឲ្យតុលាការកុំចាំបាច់សួរទៅ EDC អី ។ សំណូមពរសុំឲ្យចុងចម្លើយសងប្រាក់មកកូនក្តីខ្លួនចំនួន ៤៧០៥០$ (បួនម៉ឺនប្រាំពីរពាន់សូន្យរយហាសិបដុល្លារអាមេរិក) ការប្រាក់តាមច្បាប់គិតពីខែតុលា ឆ្នាំ ២០០៩ រហូតដល់សងប្រាក់គ្រប់ចំនួន សុំទាមទារសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា សេវាកម្មផ្សេងៗ សរុបជាប្រាក់ ៤០,០០០,០០០៛ (សែសិបលានរៀល) សុំឲ្យតុលាការសម្រេចថាសាលក្រមនេះមានអានុភាពអនុវត្តជាបណ្តោះអាសន្ន ។

-ក្រឡាបញ្ជីអានកិច្ចសន្យាផ្ទេរអគ្គិសនីចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៤ មានដូចជា:

<u>ប្រការ១</u> លោក [redacted] លឹមប៉ូល ហៅ "ភាគីក" និងលោក [redacted] កុកង៉ាន់ ហៅ "ភាគីខ" បានព្រមព្រៀងធ្វើកិច្ចសន្យាដូចខាងក្រោមនេះតទៅ:

<u>ប្រការ២</u> ភាគី "ក" បានជួលដីឲ្យភាគី "ខ" យោងតាមកិច្ចសន្យាជួលនោះក្នុងប្រការទីពីរភាគី "ក" និងភាគី "ខ" បានព្រមព្រៀងគ្នាចេញប្រាក់តបណ្តាញអគ្គិសនីដោយចេញពាក់កណ្តាលម្នាក់ក្នុងតម្លៃណាមួយនោះ ។

<u>ប្រការ៣</u> ប៉ុន្តែលុះដល់ពេលតបណ្តាញអគ្គិសនីភាគី "ខ" បានសុំខាងភាគី "ក" ដោយភាគី "ខ" បង់ប្រាក់ថ្លៃតបណ្តាញអគ្គិសនីនោះតែឯងសិនក្នុងតម្លៃ ៣៧០០០$ (បីម៉ឺនប្រាំពីរពាន់ដុល្លារអាមេរិក) ហើយលុះមុនពេលចប់កិច្ចសន្យាមួយខែភាគី "ក" ផ្ទេរយកវិញ ខាងភាគី "ក" បានយល់ព្រមតាមសំណូមពររបស់ភាគី "ខ" ។

<u>ប្រការ៤</u> ភាគី "ក" យល់ព្រមផ្ទេរយកអគ្គិសនីនោះវិញតាមការស្នើសុំរបស់ភាគី "ខ" ដោយបង់ប្រាក់សងវិញឲ្យភាគី "ខ" មុនចប់កិច្ចសន្យាមួយខែជាចំនួនទឹកប្រាក់ ៣៧០០០$ (បីម៉ឺនប្រាំពីរពាន់ដុល្លារអាមេរិក) ។

<u>ប្រការ៥</u> លុះដល់ពេលចប់កិច្ចសន្យាខាងភាគី "ក" មិនផ្ទេរយកអគ្គិសនីវិញទេនោះរាល់បញ្ហាដែលសរសេរក្នុងកិច្ចសន្យានេះភាគី "ក" និងទទួលចំពោះមុខច្បាប់ទាំងស្រុង ។

<u>ប្រការ៦</u> កិច្ចសន្យានេះ ធ្វើឡើងដោយមានការព្រមព្រៀងទាំងស្រុងរួមគ្នារបស់ភាគីទាំងពីរ ដោយការស្ម័គ្រចិត្តទាំងសងខាង ។



Scanned with CamScanner

<u>ប្រការ៧</u> កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរមានចំនួនពីរច្បាប់រក្សាទុកនៅភាគី "ក" មួយច្បាប់ ភាគី "ខ" មួយច្បាប់ដែលមានតម្លៃស្មើគ្នា និងមានប្រសិទ្ធភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

-ក្រឡាបញ្ជីអានកិច្ចសន្យាជួលដី និងអាគារចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ ដូចជា:

<u>ប្រការ១</u> ភាគី "ក" បានយល់ព្រមជួលឲ្យភាគី "ខ" នូវទីតាំងបរិវេណទាំងឡាយដូចបានពណ៌នាខាងក្រោមតាមរយ: និងលក្ខខណ្ឌដែលមាននៅក្នុងកិច្ចសន្យានេះ ។

<u>ប្រការ២</u> ភាគី "ក" បានព្រមព្រៀងជួសជុលរបស់របរមួយចំនួនឲ្យភាគី "ខ" ដូចជា: របងថ្មី.តបណ្តាញទឹក និងភ្លើង. រីឯប្រាក់កក់ភ្លើងភាគី "ក" និងភាគី "ខ" ចេញមួយនាក់ពាក់កណ្តាល លុះត្រាចប់កិច្ចសន្យាភាគី "ខ" មានសិទ្ធិដក់ប្រាក់កក់ភ្លើងពីភាគី "ក" វិញបាន។

<u>ប្រការ៣</u> ភាគី "ក" បានជួលដី និងអាគារលេខ២៣៣ ផ្លូវព្រះនរោត្តម ស្ថិតនៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ហៅ ឃ្លាំងបេ ទំហំដី ៨៤៥៦.១៣ ម៉ែត្រក្រឡា ដែលជួលក្នុងតម្លៃ ៦៥០០$ (ប្រាំមួយពាន់ប្រាំរយដុល្លាអាមេរិក) ក្នុងមួយខែ ។

<u>ប្រការ៤</u> កិច្ចសន្យានេះមានរយៈពេល៥ឆ្នាំ ដោយចាប់ផ្តើមជួលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ និងបញ្ចប់នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩ ភាគី "ខ" អាចជួលបន្តរយៈពេល៥ឆ្នាំបន្តទៀត ប៉ុន្តែមុនពេលចប់កិច្ចសន្យាភាគី "ខ" ត្រូវជូនដំណឹងទៅភាគី "ក" យ៉ាងហោចណាស់មុន៣ខែ ដើម្បីឲ្យភាគីទាំងពីរមានពេលធ្វើកិច្ចសន្យាបន្ត ។ ប៉ុន្តែការជួលនៃឆ្នាំទី៦ ឡើងទៅ បើសិនជាក្នុងករណីភាគី "ខ" មានខាតបង់ក្នុងមុខជំនួញ ឬមុខរបររបស់ខ្លួនដោយធ្វើទៅមុខមិនរួចភាគី "ខ" មានសិទ្ធិបញ្ចប់កិច្ចសន្យានេះមុនពេលកំណត់ ដោយជូនដំណឹងទៅខាងភាគី "ក" ៦ខែមុនដើម្បីឲ្យភាគី "ក" មានពេលរកភ្ញៀវមកជួលជំនួសភាគី "ខ" បន្ត ។ គិតរួមកិច្ចសន្យានេះមានរយៈពេល១០ឆ្នាំ ក៏ប៉ុន្តែចែកធ្វើកិច្ចសន្យាជាពីរដង ក្នុងមួយដងមានរយៈពេល៥ឆ្នាំ គឺ៥ឆ្នាំប្តូរកិច្ចសន្យាមួយដង ភាគី "ក" ផ្តល់ឲ្យភាគី "ខ" នូវការជួលរយៈពេល៦០ថ្ងៃដោយមិនគិតថ្លៃឈ្នួលដើម្បីឲ្យភាគី"ខ" ធ្វើការជួសជុលកែលំអ ។ រីឯប្រាក់ថ្លៃឈ្នួលត្រូវគិតចាប់ពីពេលដែលជួសជុលកែលំអអាគារនៃថ្ងៃទី ៦១ ឡើងទៅ។

<u>ប្រការ៥</u> ភាគី "ខ" បានកក់ប្រាក់ឲ្យភាគី "ក" ចំនួនបួនខែ សរុបទឹកប្រាក់ ២៦០០០$ (ពីរម៉ឺនប្រាំមួយពាន់ដុល្លាអាមេរិក ) ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ប្រការ៦</u> ការបង់ប្រាក់ឈ្នួលមិនឲ្យយឺតហួសពីថ្ងៃទី ១០ ជារៀងរាល់ខែ តែបើហួសពីថ្ងៃទី ១០ នោះភាគី "ខ" ត្រូវទទួលការពិន័យ ៥% ក្នុងមួយថ្ងៃនៃទឹកប្រាក់ដែលត្រូវបង់ ប៉ុន្តែបើយឺតយ៉ាវរហូតដល់០៣ខែឡើងទៅភាគី "ក" មានសិទ្ធិរឹបអូសយកប្រាក់កក់ហើយកិច្ចព្រមព្រៀងជួលនោះត្រូវចប់ដោយស្វ័យប្រវត្តទោះកិច្ចសន្យានោះមិនទាន់ផុតកុងត្រាក់ដោយ ។

<u>ប្រការ៧</u> កិច្ចសន្យានេះភាគី "ខ" មានសិទ្ធិក្នុងការផ្ទេរ ឬជួលបន្តទីតាំងជួលនោះទាំងមូល ឬផ្នែកខ្លះទៅអោយអ្នកណាក៏បានដែរ ។ ប៉ុន្តែភាគី "ខ" ត្រូវជូនដំណឹងទៅភាគី "ក" ជាមុនសិន ។ ក្នុង

ករណីភាគី "ខ" ជួលដី និងអាគារខាងលើនេះឲ្យទៅភាគីផ្សេងខុសច្បាប់រដ្ឋនោះភាគី "ខ" ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

ប្រការ៨ ភាគី "ក" និងភាគី "ខ" បានឯកភាពជួយចេញចំណាយរួមគ្នាសម្រាប់បង់ពន្ធអាករលើថ្លៃឈ្នួលឃ្លាំងបេ (VAT) តាមការកំណត់ដូចជា: ភាគី "ក" ជួយចេញ ៣៥០$ (បីរយហាសិបដុល្លាអាមេរិក) ភាគី "ខ" ជួយចេញ ៣០០$ (បីរយដុល្លាអាមេរិក) ភាគី "ខ" មានភារកិច្ចបង់ប្រាក់នេះទៅឲ្យភាគី "ក" ព្រមពេលជាមួយការបង់ថ្លៃឈ្នួលឃ្លាំងបេជារៀងរាល់ខែ ហើយភាគី "ក" ត្រូវទទួលខុសត្រូវក្នុងការបង់បង្គ្រប់ជូនរដ្ឋ ។

ប្រការ៩ រីឯប្រាក់កក់៤ខែនោះភាគី "ខ" មិនអាចយកវិញបានទេត្រូវទុកកាត់កង៤ខែចុងក្រោយនៃបញ្ចប់កិច្ចសន្យាប៉ុណ្ណោះ ។

ប្រការ១០ ឯកសារនោះមានការព្រមព្រៀងទាំងស្រុង និងរួមគ្នារបស់ភាគីទាំងពីរ ហើយមិនអាចធ្វើការផ្លាស់ប្តូរបានឡើយ លើកលែងតែមានសំណើរជាលាយលក្ខណ៍អក្សរ និងទទួលស្គាល់ដោយភាគីទាំងពីរ ។

៣-ការពន្យល់ត្រួសៗអំពីរឿងក្តី

៣-១ អង្គហេតុដែលជាមូលហេតុនៃការទាមទារ

-តាមកិច្ចសន្យាជួលដី និងអាគារចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ ភាគីចុងចម្លើយបានជួលដី និងអាគារលេខ២៣៣ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ហៅ ឃ្លាំងបេ ពីដើមចោទក្នុងតម្លៃ ៦៥០០$ (ប្រាំមួយពាន់ប្រាំរយដុល្លាអាមេរិក) ក្នុងមួយខែ ។ ការបង់ប្រាក់ឈ្នួលរបស់ចុងចម្លើយ ការប្រព្រឹត្តទៅជាធម្មតា តែចាប់ពីខែ តុលា ឆ្នាំ ២០០៨ រហូត ដល់ខែ មិថុនា ឆ្នាំ ២០០៩ ចុងចម្លើយមិនបានបង់ប្រាក់ឈ្នួលដែលជាកាតព្វកិច្ចរបស់ខ្លួនមកភាគីដើមចោទទេ ក្រោយមកនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ភាគីចុងចម្លើយបានធ្វើលិខិតទទួលស្គាល់ថាពិតជានៅជំពាក់ប្រាក់ដើមចោទចំនួន ៥១០៥០$ (ប្រាំម៉ឺនមួយពាន់សូន្យរយហាសិបដុល្លាអាមេរិក) ប្រាកដមែន ។ ក្រោយពីបានធ្វើលិខិតទទួលស្គាល់បំណុលរួចហើយ ភាគីចុងចម្លើយនៅមិនទាន់ធ្វើការទូទាត់ប្រាក់ឈ្នួលនេះមកភាគីដើមចោទទេ ទោះបីជាមានការទាមទារក៏ដោយ ។

៣-២ ការតវ៉ា

-មូលហេតុដែលភាគីចុងចម្លើយមិនបង់ប្រាក់ឈ្នួលទីតាំងនេះ ដោយសារលោក [redacted] លឹម ប៉ូល មិនគោរពតាមកិច្ចសន្យាជួលចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ ដែលកិច្ចសន្យាជួលនេះមានថិរវេលា១០ឆ្នាំ ដែលត្រូវធ្វើកិច្ចសន្យាជួល៥ឆ្នាំម្តង ។ នៅមុនពេលចប់កិច្ចសន្យាជួលភាគី "ខ" ត្រូវជូនដំណឹងឲ្យភាគី "ក" យ៉ាងហោចណាស់មុន៣ខែ ដើម្បីឲ្យភាគីទាំងពីរមានពេលធ្វើកិច្ចសន្យាបន្តទៀត ។ ក្នុងការបំពេញកាតព្វកិច្ចនេះចុងចម្លើយបានព្យាយាមទំនាក់ទំនងលោក [redacted] លឹមប៉ូល

ប៉ុន្តែមិនអាចទំនាក់ទំនងបាន ពីព្រោះគាត់មានទីលំនៅ នៅឯសហរដ្ឋអាមេរិក ។ ក្នុងអំឡុងឆ្នាំ ២០០៩ តំណាងរបស់លោក [redacted] លឹមប៉ូល បានមកទារប្រាក់ថ្លៃឈ្នួលទីតាំងពីចុងចម្លើយ នៅពេលនោះចុងចម្លើយមិនបង់ប្រាក់ជូនទេ ដោយស្នើសុំឲ្យដើមចោទមកជួបដើម្បីបន្តកិច្ចសន្យាជាថ្មីទៀត ចុងចម្លើយបានស្នើទៅដើមចោទបន្តកិច្ចសន្យាជួលទីតាំងរយៈពេល៥ឆ្នាំទៀត ប៉ុន្តែដើមចោទថាអស់សិទ្ធិនៅលើទីតាំងនេះហើយ ពេលនោះចុងចម្លើយបានសុំឲ្យដើមចោទទូទាត់ប្រាក់ទៅវិញទៅមក គឺប្រាក់ដែលចុងចម្លើយជំពាក់ថ្លៃឈ្នួលទីតាំង ជាមួយនិងប្រាក់កក់ចំនួន៤ខែ ស្មើនឹងចំនួន ២៦០០០$ (ពីរម៉ឺនប្រាំមួយពាន់ដុល្លារអាមេរិក) និងប្រាក់ថ្លៃចរន្តអគ្គិសនីចំនួន ៣៧០០០$ (បីម៉ឺនប្រាំពីរពាន់ដុល្លារអាមេរិក) ដែលដើមចោទមានកាតព្វកិច្ចត្រូវសងមកចុងចម្លើយវិញ តាមកិច្ចសន្យាផ្ទេរអគ្គិសនីចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៤ ពេលនោះដើមចោទបានយល់ព្រមធ្វើការទូទាត់គ្នា ប៉ុន្តែទូទាត់ហើយឃើញថា ដើមចោទត្រូវជំពាក់ចុងចម្លើយវិញចំនួន ១៥៩៥០$ (មួយម៉ឺនប្រាំពាន់ប្រាំបួនរយហាសិបដុល្លារអាមេរិក) ឃើញដូច្នេះភាគីដើមចោទក៏បានគេចវេសមិនចូលមកដោះស្រាយបំណុល និងបន្តកិច្ចសន្យាជាថ្មីរហូតមកដល់សព្វថ្ងៃនេះ ។

-ក្រឡាបញ្ជីអានលិខិតទទួលស្គាល់បំណុលចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩៖ ខ្ញុំបាទឈ្មោះ [redacted] កុកង៉ាន់ នៅជំពាក់ថ្លៃឈ្នួលទីតាំងឃ្លាំងបេរបស់លោក [redacted] លឹមប៉ូល ចំនួនទឹកប្រាក់ស្មើ ៥១០៥០$ (ប្រាំម៉ឺនមួយពាន់ហាសិបដុល្លារអាមេរិក)។

**ចំណុចវិវាទក្នុងរឿងក្តី**

ដើមចោទម្ចាស់ទីតាំងអាគារលេខ ២៣៣ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ និងចុងចម្លើយជាភាគីអ្នកជួល តើមានការទូទាត់ថ្លៃប្រាក់តបណ្តាញអគ្គិសនីចំនួន ៣៧០០០$ (បីម៉ឺនប្រាំពីរពាន់ដុល្លារអាមេរិក) និងថ្លៃកក់ ឈ្នួលឃ្លាំងចំនួន ៤ខែ ស្មើនឹង ២៦០០០$ (ពីរម៉ឺនប្រាំមួយពាន់ដុល្លារអាមេរិក) ហើយឬនៅ?

-បានឃើញ ពាក្យបណ្តឹងរបស់ឈ្មោះ [redacted] លឹមប៉ូល ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១ ។

-បានឃើញ ពាក្យបណ្តឹងតបរបស់ឈ្មោះ [redacted] កុកង៉ាន់ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១១ ។

-បានឃើញ លិខិតទទួលស្គាល់បំណុលចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩

-បានឃើញ កិច្ចសន្យាជួលដី និងអាគារចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤។

-បានឃើញ កិច្ចសន្យាផ្ទេរអគ្គិសនីចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៤ ។

-បានឃើញ កំណត់ហេតុត្រៀមទាញហេតុផលលើកទី១ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ ។

-បានឃើញ កំណត់ហេតុត្រៀមទាញហេតុផលលើកទី២ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១ ។

## សំអាងហេតុ

-តាមកិច្ចសន្យាជួលដី និងអាគារចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ រវាងឈ្មោះ [redacted] លឹម ប៉ូល និងឈ្មោះ [redacted] កុកង៉ាន់ បានបញ្ជាក់ឲ្យឃើញថា: ចុងចម្លើយពិតជាបានចុះកិច្ចសន្យាជួលដី និងអាគារដែលមានរយៈពេល ១០ឆ្នាំ តែត្រូវធ្វើកិច្ចសន្យាម្តង ៥ឆ្នាំ ដែលចាប់ផ្តើមជួលពីថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ និងបញ្ចប់នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩ ក្នុងតម្លៃជួលក្នុងមួយខែចំនួន ៦៥០០$ (ប្រាំមួយពាន់ប្រាំរយដុល្លាអាមេរិក) ហើយបានកក់ប្រាក់៤ខែចំនួន ២៦០០០$ (ពីរម៉ឺនប្រាំមួយពាន់ដុល្លាអាមេរិក) និងបានចេញប្រាក់ផ្ទាល់ខ្លួនតបណ្តាញអគ្គិសនីចំនួន ៣៧០០០$ (បីម៉ឺនប្រាំពីរពាន់ដុល្លាអាមេរិក) តាមកិច្ចសន្យាផ្ទេរអគ្គិសនីចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៤ ប្រាកដមែន ។

-តាមការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យគូភាគីឃើញថា: ចុងចម្លើយឈ្មោះ [redacted] កុកង៉ាន់ បានទទួលស្គាល់ថា ពិតជាបានជំពាក់ប្រាក់ឈ្នួលទីតាំងរបស់ដើម ចោទចំនួន ៥១០៥០$ (ប្រាំម៉ឺនមួយពាន់ហាសិបដុល្លាអាមេរិក) មែន តាមលិខិតចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ចំណុចនេះមេធាវីតំណាងដោយ អាណត្តិរបស់ចុងចម្លើយបានថ្លែងការណ៍ថា: នៅក្នុងរឿងនេះដើមចោទក៏នៅជំពាក់ថ្លៃតបណ្តាញ អគ្គិសនីចំនួន ៣៧០០០$ (បីម៉ឺនប្រាំពីរពាន់ដុល្លាអាមេរិក) និងប្រាក់កក់ចំនួន ២៦០០០$ (ពីរម៉ឺនប្រាំមួយពាន់ដុល្លាអាមេរិក) សរុបស្មើ ៦៣០០០$ (ប្រាំមួយម៉ឺនបីពាន់ដុល្លាអាមេរិក) ពេលធ្វើការទូទាត់ គ្នាទៅឃើញថាដើមចោទនៅជំពាក់កូនក្តីខ្លួនចំនួន ១១៩៥០$ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបដុល្លាអាមេរិក) វិញ តែបំណុលចំនួន ៥១០៥០$ លោក [redacted] កុកង៉ាន់ ពុំបាននិយាយសំរាប់ទូទាត់ថ្លៃតបណ្តាញអគ្គិសនី និង ថ្លៃប្រាក់កក់ទេ មានន័យថា គូភាគីបានទូទាត់កាត់កងគ្នារួចអស់ហើយទើបទទួលស្គាល់បំណុលចុងក្រោយចំនួន ៥១០៥០$ (ប្រាំម៉ឺនមួយពាន់សូន្យរយហាសិបដុល្លាអាមេរិក) ។ រីឯប្រាក់ចំនួន ៤០០០$(បួនពាន់ដុល្លាអាមេរិក) ទៀតដែលចុងចម្លើយអះអាងថាបានទូទាត់ឲ្យលោក [redacted] លឹមប៉ូល នៅវិក័យប័ត្រពីរសន្លឹក សរុបទៅលោក [redacted] លឹមប៉ូល គឺនៅខ្វះលុយកូនក្តីខ្លួនចំនួន ១៥៩៥០$ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបដុល្លាអាមេរិក)។ ប្រាក់ចំនួន ៤០០០$ (បួនពាន់ដុល្លាអាមេរិក) នេះដើមចោទ ទទួលស្គាល់ពិតជាមានការសងមែន តែសងនៅក្រោយពេលដែលចុងចម្លើយទទួលស្គាល់បំណុលរួម ៥១០៥០ $ (ប្រាំម៉ឺនមួយពាន់សូន្យរយហាសិបដុល្លាអាមេរិក) ដើមចោទកាត់កងនៅសល់ប្រាក់ដែលចុងចម្លើយខ្វះមានចំនួន ៤៧០៥០ $ (បួនម៉ឺនប្រាំពីរពាន់សូន្យរយហាសិបដុល្លាអាមេរិក) ប៉ុន្តែប្រាក់កក់ទាំងបួនខែ និងប្រាក់តបណ្តាញអគ្គិសនីគឺ គូភាគីបានធ្វើការទូទាត់កាត់កងគ្នារួចអស់ហើយ ទើបមានកិច្ចសន្យាចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលជាកិច្ចសន្យាទទួលស្គាល់បំណុលចុងក្រោយដោយឈ្មោះ [redacted] កុកង៉ាន់ គឺ មានចំនួន ៥១០៥០$ (ប្រាំម៉ឺនមួយពាន់សូន្យរយហាសិបដុល្លាអាមេរិក) ។

-ការលើកឡើងរបស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ ដែលប្តឹងសុំឲ្យដើមចោទសងប្រាក់កក់ចំនួនបួនខែសរុបស្មើចំនួន ២៦០០០$ (ពីរម៉ឺនប្រាំមួយពាន់ដុល្លារអាមេរិក) និងប្រាក់ថ្លៃតបណ្តាញទឹក និង បណ្តាញអគ្គីសនីសរុបចំនួន ៣៧០០០$ (បីម៉ឺនប្រាំពីរពាន់ដុល្លារអាមេរិក) មកកូនក្តីខ្លួនវិញ ដោយអះអាងថាដើមចោទមិនទាន់បានកាត់កងមកឲ្យកូនក្តីខ្លួន តាមកិច្ចសន្យានៅឡើយនោះ ឃើញថាមានហេតុផលមិនសមរម្យទេដោយហេតុថាកិច្ចសន្យាជួលទី តាំងត្រូវបានបញ្ចប់ទៅហើយរហូតដល់មានការទូទាត់បំណុលចុងក្រោយ ព្រមទាំងបានធ្វើកិច្ចសន្យាចុងក្រោយចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដោយចុងចម្លើយទទួលស្គាល់ថានៅជំពាក់ប្រាក់ដើមចោទចំនួន ៥១០៥០$ (ប្រាំម៉ឺនមួយពាន់សាមសិបដុល្លារអាមេរិក) ថែមទៀតផង បើសិនជាដើមចោទនៅខ្វះប្រាក់ថ្លៃបណ្តាញអគ្គីសនីនិងប្រាក់កក់ចំនួន៤ដងមែន ប្រាកដជាគូភាគីធ្វើកិច្ចសន្យាព្រមគ្នា កាត់កងគ្នាតែម្តង ។ ដូច្នេះការអះអាងរបស់មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយពុំមានមូលដ្ឋានច្បាស់លាស់ អាចឲ្យតុលាការជឿបានឡើយ គប្បីច្រានចោលការប្តឹងទាមទាររបស់ចុងចម្លើយ ។

-ចុងចម្លើយអះអាងថាបានសងប្រាក់ចំនួន ៤០០០$(បួនពាន់ដុល្លារអាមេរិក)តាមវិក័យបត្រចំនួនពីរសន្លឹកគឺ វិកយបត្រលេខ០០៦០៧៥ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៩ និង វិកយបត្រលេខ០០៥៩៨៦ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៩ ហើយមេធាវីតំណាងដោយអាណត្តិរបស់ដើមចោទក៏បានទទួលស្គាល់ថា ចុងចម្លើយពិតជាបានសងមែនដែលការសងនេះធ្វើនៅក្រោយពេលទទួលស្គាល់បំណុលចំនួន ៥១០៥០$ (ប្រាំម៉ឺនមួយពាន់សាមសិបដុល្លារអាមេរិក) ដូច្នេះចុងចម្លើយនៅជំពាក់ប្រាក់ដើមចោទចំនួន ៤៧០៥០$ (បួនម៉ឺនប្រាំពីរពាន់សាមសិបដុល្លារអាមេរិក)។

-ដើមចោទបានប្តឹងទាមទារប្រាក់ឈ្នួលទីតាំងចំនួន ៤៧០៥០$ (បួនម៉ឺនប្រាំពីរពាន់សាមសិបដុល្លារអាមេរិក) មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ។ ប៉ុន្តែ ចំណុចដែលដើមចោទបានទាមទារប្រាក់ជម្ងឺចិត្តសេវាកម្មច្បាប់ និងចំណាយសម្រាប់រឿងក្តីសរុប ចំនួន ៤០.០០០.០០០ (សែសិបលានរៀល) ពីចុងចម្លើយឃើញថាមានចំនួនច្រើនពេក ដូច្នេះតុលាការនិងពិនិត្យពិចារណាតាមភាពសមរម្យ ។ រីឯការទាមទារការប្រាក់ ៥% (ប្រាំភាគរយ) ក្នុងមួយឆ្នាំគឺពុំត្រឹមត្រូវទេ ពីព្រោះវិក័យបត្រចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ចុងចម្លើយទទួលស្គាល់បំណុលចំនួន៥១០៥០$ (ប្រាំម៉ឺនមួយពាន់សាមសិបដុល្លារអាមេរិក) មែនតែពុំបាននិយាយពីការប្រាក់ទេ គប្បីច្រានចោលលើចំណុចនេះយោងមាត្រា៥៨នៃក្រឹតច្បាប់លេខ៣៨ក្រ.ចស្តីពីការទទួលខុសត្រូវក្រៅកិច្ចសន្យា។µ

-ការស្នើសុំរបស់ដើមចោទ ឲ្យមានការអនុវត្តបណ្ដោះអាសន្ន លើសាលក្រមនេះ ចំណុចនេះតុលាការមិនអនុញ្ញាតិឲ្យតាមសំណូមពរទេ ពីព្រោះរឿងនេះកំពុងស្ថិតនៅកំពុងវិវាទគ្នានៅឡើយ។

-ចុងចម្លើយជាអ្នកមានកំហុសមិនព្រមសងប្រាក់ឲ្យដើមចោទតាមកិច្ចសន្យា ដូច្នេះត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្ដី យោងមាត្រា ៦៤ នៃកថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ហេតុដូច្នេះសម្រេច**

១- បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] កុកង៉ាន់ សងប្រាក់ចំនួន ៤៧០៥០$ (បួនម៉ឺនប្រាំពីរពាន់សូន្យរយហាសិបដុល្លាអាមេរិក) និងជំងឺចិត្ត៣៥លានរៀល (សាមសិបប្រាំលានរៀល) ឲ្យទៅដើមចោទឈ្មោះ [redacted] លឹមប៉ូល ។ ការទាមទារការប្រាក់ ការទាមទារសុំឲ្យអនុវត្តបណ្ដោះអាសន្ននិងការទាមទារប្រាក់ជំងឺចិត្តលើសពីនេះត្រូវច្រានចោល។

២- ច្រានចោលការទាមទារមេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ។

៣- ប្រាក់ប្រដាប់ក្ដីគឺជាបន្ទុករបស់ចុងចម្លើយ ។

៤- សាលក្រមនេះបានធ្វើការទាញហេតុផលផ្ទាល់មាត់នាថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២១ខែ កញ្ញា ឆ្នាំ ២០១១ ។

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា: [redacted]

---

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១១

ក្រឡាបញ្ជី

[redacted]